ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**
លេខ :១៥៣៩ វ.ប.ក

# សេចក្តីជូនដំណឹងលើកទី២
# ស្តីពីការផ្គត់ផ្គង់សម្ភារនិងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា ឆ្នាំ២០១៨
# ជូនវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារនិងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា សម្រាប់ឆ្នាំ២០១៨ ជូនវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្មនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលមានអាសយដ្ឋាន មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ (+855) 23 880 370 )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅម៉ោង០៩:៣០នាទីព្រឹក ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្មតាមអាសយដ្ឋានខាងលើ វេលាម៉ោង០៩:៣០នាទីព្រឹក ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

**នាយកវិទ្យាស្ថាន**
**និងជាប្រធានក្រុមលទ្ធកម្ម**

បណ្ឌិត អ៊ុម រម្យណី

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ - កាលប្បវត្តិ